# ការទស្សនាកន្លែងថតវីដេអូព្រះគម្ពីរមរមន

ដោយគណៈប្រធានអង្គការបឋមសិក្សាទូទៅ

មិនយូរប៉ុន្មានកន្លងទៅ យើងបានទៅទស្សនាកន្លែងថតមួយកន្លែង ដែលកំពុងថតវីដេអូព្រះគម្ពីរមរមនថ្មី ។ យើងបានទៅមើលឈុតមួយ ដែលព្រះយេស៊ូវគ្រីស្ទបានយាងមកជួបនឹងកុមារម្តងម្នាក់ៗ ។

យើងបានមើលទៅកុមារនៅពេលបានប៉ះដៃរបស់តួអង្គដែលកំពុងសម្តែងជាព្រះយេស៊ូវ ។ លោកបាននិយាយទៅកាន់ពួកគេដោយចិត្តសប្បុរសទន់ភ្លន់ដូចដែលព្រះយេស៊ូវគ្រីស្ទបានធ្វើ ។

កុមារទាំងនោះបានប្រាប់យើងថា ដោយសារបទពិសោធន៍របស់ពួកគេនោះទីបន្ទាល់របស់ពួកគេអំពីព្រះគម្ពីរមរមនបានកើនឡើងកាន់តែរឹងមាំ ។ ព្រះយេស៊ូវ *បាន* មកជួបពួកសាសន៍នីហ្វៃ ។ ទ្រង់ *បាន* ប្រទានពរដល់កុមារទាំងឡាយ ។ ដំណើររឿងនេះគឺពិត ។

ប្អូនៗក៏អាចដឹងពីរឿងនោះផងដែរ ។ សូមសិក្សាព្រះគម្ពីរមរមន ។ សូមទស្សនាវីដេអូព្រះគម្ពីរមរមន ។ ពេលប្អូនៗមើលវីដេអូទាំងនេះ នោះប្អូនៗអាចខិតទៅជិតព្រះយេស៊ូវ ។ ប្អូនៗគឺជាមនុស្សសំខាន់បំផុតចំពោះទ្រង់ ។ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងជួយប្អូនឲ្យមានអារម្មណ៍នៃសេចក្តីស្រឡាញ់ និងសេចក្តីសុខសាន្តរបស់ព្រះអង្គសង្គ្រោះ ។●



តួអង្គដែលសម្តែងជាព្រះយេស៊ូវមានចិត្តល្អ និងទន់ភ្លន់ ។



នៅក្នុងឈុតនេះ ពួកទេវតាត្រូវបានចងនៅលើអាកាសដោយខ្សែពួរ !





កុមារីនេះបានជួយអ្នកកាន់កាមេរ៉ាកុំឲ្យភ័យ ។



គណៈប្រធានអង្គការបឋមសិក្សាមានចិត្តរីករាយក្នុងការជួបកុមារនៅកន្លែងថតវីដេអូនេះ ។





កុមារជាច្រើនបានមានឱកាសសម្តែងនៅក្នុងវីដេអូនេះ ។

បងប្អូនអាចទស្សនាវីដេអូព្រះគម្ពីរមរមនបាន នៅលើគេហទំព័រ **ChurchofJesusChrist.org** ។

វាមានអារម្មណ៍ថា ខ្ញុំ កំពុងរស់នៅ នៅក្នុងព្រះគម្ពីរមរមនអញ្ចឹង ។
អ៊ីម៉ូអានី ដបុលយូ អាយុ ១១ ឆ្នាំ

វាបានជួយខ្ញុំឲ្យដឹងថា ព្រះយេស៊ូវបានយាងមកជួបប្រជាជនទាំងនេះមែន ។
អាយហ្សឹក ភី អាយុ ៧ ឆ្នាំ

នៅពេលដែលព្រះយេស៊ូវ និងពួកទេវតាបានបង្ហាញព្រះកាយ វាបានធ្វើឲ្យខ្ញុំមានចិត្តសប្បាយរីករាយ ។
លីលី ដបុលយូ អាយុ ៨ ឆ្នាំ

បងប្អូនអាចចែកចាយវីដេអូនេះជាមួយមនុស្សគ្រប់គ្នាបាន !
ខាសសុល ដបុលយូ អាយុ ៩ ឆ្នាំ

បងប្អូននឹងរៀនបន្ថែមទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។
គ្រីស្ទីណា ស៊ី អាយុ ៩ ឆ្នាំ

វាធ្វើឲ្យខ្ញុំឆ្ងល់ថា តើវានឹងមានសភាពបែបណា នៅពេលជួបព្រះយេស៊ូវនោះ ។
បត អឹម អាយុ ៤ ឆ្នាំ

